ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ
នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ

**សូមគោរពជូន**
**ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម**

<u>កម្មវត្ថុ:</u> *របាយការណ៍នៃកិច្ចប្រជុំរវាង DICO និង IAs ប្រចាំខែមិថុនា*
<u>យោង:</u> *លិខិតអញ្ជើញលេខ ២៣៩៣ ពណ-សហអ ចុះថ្ងៃទី ១០ មិថុនា ២០១១*

*តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំបាទមានកិត្តិយស សូមគោរព និង រាយការណ៍ ជូន* **ឯកឧត្តម ទេសរដ្ឋមន្ត្រី** *មេត្តាជ្រាបថា: កាលពីថ្ងៃទី ១៦ មិថុនា ២០១១ DICO បានរៀបចំកិច្ចប្រជុំប្រចាំខែជាមួយ ភ្នាក់ងារអនុវត្តគម្រោង IAs (Implementing Agencies) ដើម្បីជំរុញការអនុវត្តន៍គម្រោង TDSP ។ ខ្ញុំបាទសូមអនុញ្ញាតរាយការណ៍ជូននូវចំណុចសំខាន់ៗដូចខាងក្រោម:*

*ក)- របាយការណ៍វឌ្ឍនៈភាពរបស់គម្រោង TDSP*

- *រហូតមកទល់ពេលនេះ មាន MoU ចំនួន ១៨ ត្រូវបានចុះហត្ថលេខា ជាមួយ IAs ចំនួន ១៣ ។*
- *ផ្សព្វផ្សាយអំពីកាលបរិច្ឆេទនៃកិច្ចប្រជុំប្រចាំឆ្នាំរបស់ SSC-TD-TRI, IC, និង DICO and IAs meeting (ដូចមានភ្ជាប់នៅក្នុង Presentation Slides)*
- *ប្រគល់ភារៈកិច្ចឲ្យមន្ត្រី LO (Liaison Official) របស់ DICO ទទួលបន្ទុកប្រចាំ IAs នីមួយៗ*
- *វឌ្ឍនៈភាពក្នុងការអនុវត្តន៍ Benchmarks របស់ធនាគារពិភពលោក (សូមពិនិត្យក្នុង Presentation Slides)*

ខ)- បានធ្វើការរៀបចំផែនការថវិកាលំអិតស្តីពីការធ្វើសិក្ខាសាលា, វគ្គបណ្តុះបណ្តាល ទាំងក្នុងនិងក្រៅប្រទេសរបស់ភ្នាក់ងារអនុវត្តគម្រោងរួមមាន:

- នាយកដ្ឋានពហុភាគី
- នាយកដ្ឋានជំរុញពាណិជ្ជកម្ម
- វិទ្យាស្ថានស្តង់ដាកម្ពុជា
- នាយកដ្ឋានស្ថិតិ និងពត៌មានពាណិជ្ជកម្ម
- អគ្គនាយកដ្ឋានគយ និងរដ្ឋាករ
- សាលាភូមិន្ទរដ្ឋបាល
- នាយកដ្ឋានកម្មសិទ្ធិបញ្ញា
- នាយកដ្ឋាននីតិកម្ម
- នាយកដ្ឋានបុគ្គលិក
- អគ្គនាយកដ្ឋានាកាំកុងត្រូល
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

គ)- ការផ្សព្វផ្សាយអំពីការគ្រប់គ្រងហិរញ្ញវត្ថុ

ផ្នែកហិរញ្ញវត្ថុរបស់ DICO បានធ្វើការផ្សព្វផ្សាយ និងណែនាំដល់ IAs ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុរបស់គម្រោងមានដូចខាងក្រោម:

- ការទូទាត់ និងសំណើសុំបំពេញបេឡាសាច់ប្រាក់
- សំណើសុំទូទាត់ចំណាយជូនទីប្រឹក្សាជាតិ និងអន្តរជាតិ
- រាល់ការចំណាយទាំងអស់ត្រូវមាននៅក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ

កិច្ចប្រជុំបានបញ្ចប់មុនកាលកំណត់ ដោយផ្នែកហិរញ្ញវត្ថុត្រូវទៅចូលរួមប្រជុំស្តីពីការកែសម្រួល SFMM ដែលរៀបចំឡើងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម ទេសរដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់ ។

សូម **ឯកឧត្តម ទេសរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២២ មិថុនា ២០១១

**ប្រធាននាយកដ្ឋាន**

ឈៀង ពេជ្រ